# ACCESSIBLE MT BAKER

សន្លឹកព័ត៌មាន

ខែវិច្ឆិកា ឆ្នាំ 2019

## ការកែលម្អផ្លូវដើរ/ជិះកង់ក្នុងពេលដ៏ឆាប់ខាងមុខ



ផ្លូវប្រសព្វ Rainier Ave S និង Martin Luther King Jr Way S ស្ថិតនៅចំកណ្តាលទិសដៅសំខាន់ៗ ដូចជាស្ថានីយ៍រថភ្លើងធនស្រាល Mt Baker Link Light Rail Station មជ្ឈមណ្ឌលប្តូររថភ្លើងក្រោមដី King County Metro Transit Center វិទ្យាល័យ Franklin High School គេហដ្ឋាន និងហាងលក់រាយ។

## ទិដ្ឋភាពទូទៅ

តំបន់ស្ថានីយ៍ Mt Baker Station Area បានផ្តោតសំខាន់លើដំណើរការរៀបចំមួយចំនួនក្នុងរយៈពេល 10 ឆ្នាំកន្លងមក ដែលសហគមន៍បានបង្ហាញចក្ខុវិស័យសម្រាប់ទីប្រជុំជនដែលមានភាពសម្បូរបែប ពិពិធភាព និរន្តរភាព និងតម្លៃសមរម្យ។

ផ្នែកមួយនៃចក្ខុវិស័យនោះគឺធ្វើអោយប្រសើរឡើងនូវសុវត្ថិភាពនៃការដឹកជញ្ជូន និងការតភ្ជាប់ ហើយបច្ចុប្បន្ននេះ យើងកំពុងអភិវឌ្ឍ**កែលម្អផ្លូវដើរ/ជិះកង់ក្នុងពេលដ៏ឆាប់ខាងមុខនេះ**ដើម្បីជួយអោយប្រជាជនធ្វើដំណើរទៅកាន់មជ្ឈមណ្ឌលឆ្លងកាត់ និងស្ថានីយ៍រថភ្លើងធន់ស្រាលនៅ Rainier និង MLK។

ផ្អែកលើការចុះផ្សព្វផ្សាយកន្លងមក យើងបានរាយនូវគំនិតកែលម្អដ៏មានសក្តានុពលក្នុងពេលដ៏ឆាប់ខាងមុខ (សូមមើលផែនទីនៅផ្នែកខាងក្រោយ)។ នៅចុងឆ្នាំនេះ យើងនឹងជ្រើសរើសយកមួយណាដែលឆ្ពោះទៅមុខដើម្បីអភិវឌ្ឍការរចនា ដោយផ្អែកលើការចំណាយ/អត្ថប្រយោជន៍ និងការចូលរួមរបស់សហគមន៍។ យើងនឹងធ្វើការកែលម្អនៅឆ្នាំ 2024។

**ធ្វើការស្ទង់មតិរបស់យើង!**

យើងចង់ស្តាប់ពីមនុស្សដែលរស់នៅ ធ្វើការ ដើរផ្សារ និងធ្វើដំណើរឆ្លងកាត់តំបន់នោះ។ ដាក់ចំណាត់ថ្នាក់ជម្រើសគម្រោងរបស់អ្នកនៅក្នុងការស្ទង់មតិតាមអនឡាញត្រឹមថ្ងៃទី11 ខែធ្នូ!

www.surveymonkey.com/r/AMB_Survey



ព្រឹត្តិការណ៍នៃការចុះផ្សព្វផ្សាយជាមួយសិស្សវិទ្យាល័យ Franklin High School នៅ Mt Baker Hub (ស្នាដៃរូបថត៖ Mt Baker Hub)


### ស្វែងយល់បន្ថែម

www.seattle.gov/transportation/projects-and-programs/programs/transportation-planning/accessible-mt-baker

AMB@seattle.gov or 206-775-8720

# ការកែលម្អផ្លូវដើរ/ជិះកង់ដ៏មានសក្តានុពលនៅ MT BAKER ដែលអាចប្រើប្រាស់បាន

## ការកែលម្អដ៏មានសក្តានុពលទាំងនេះកំពុងត្រូវបានត្រួតពិនិត្យដើម្បីសាងសង់នៅឆ្នាំ 2024។




1 ពង្រីកជ្រុងផ្លូវដើរ (ជាពិសេស "បន្ថែមការពង្រីកជ្រុងរាងកោងដូចអំពូលពងមាន់"

2 ពង្រីក និងជួសជុលផ្លូវដើរ

3 ពង្រីកផ្លូវឆ្លងកាត់

4 ផ្លាស់ប្តូរផ្លូវខាងជើងនៃ Mt Baker Blvd សម្រាប់តែដើរ/ជិះកង់

5 មិនអាចបត់ស្តាំពេលភ្លើងក្រហមឆ្ពោះទៅជើងពី Rainier ទៅ MLK

6 ការកែលម្អជាលក្ខណៈសិល្បៈសម្រាប់ស្ពានអ្នកថ្មើរជើង

7 ផ្លូវឆ្លងកាត់ថ្មី (រួមទាំង ការប្តូរទីតាំងសញ្ញាដែលមានស្រាប់)

8 កែលម្អផ្លូវថ្មើរជើងឆ្លងកាត់នៅ Rainier/McClellan និង MLK/McClellan

កំណត់សម្គាល់៖ បច្ចុប្បន្ននេះ យើងកំពុងបន្ថែម "រយៈពេលអ្នកថ្មើរជើងឆ្លងកាត់បន្ថែមមុនភ្លើងបៃតង" ចូលក្នុងផ្លូវប្រសព្វចម្បងនីមួយៗនៅលើផែនទីនេះ។ រយៈពេលអ្នកថ្មើរជើងឆ្លងកាត់បន្ថែមមុនភ្លើងបៃតងគឺជាការផ្លាស់ប្តូរពេលវេលានៃសញ្ញាដែលផ្តល់ឱ្យអ្នកថ្មើរជើងដើរមុនដើម្បីឆ្លងកាត់ផ្លូវមុនពេលអ្នកបើកបរទទួលបានភ្លើងបៃតង។ ពួកវាធ្វើឱ្យគេមើលឃើញអ្នកថ្មើរជើងកាន់តែច្បាស់

ការរចនាដំបូង
ហើយការរចនាចុងក្រោយ
និងសំណាងបច្ចុប្បន្នេះមិនទាន់មានថវិកានៅឡើយទេ។

## ការងារ MT BAKER ដែលអាចមានលទ្ធភាពប្រើប្រាស់បានផ្សេងទៀត

បន្ថែមលើការកែលម្អក្នុងរយៈពេលដ៏ឆាប់ខាងមុខ យើងក៏កំពុងធ្វើការលើកិច្ចខិតខំប្រឹងប្រែងទាំងនេះដែលដើរតួជាជំហានឆ្ពោះទៅរកចក្ខុវិស័យកាន់តែប្រសើរឡើង៖

1. យើងកំពុងធ្វើការជាដៃគូជាមួយ King County Metro និង Sound Transit ដើម្បីសិក្សាពី**លទ្ធភាពដែលអាចធ្វើការផ្លាស់ប្តូរទីតាំង Metro Transit Center ទៅជិត Mt Baker Light Rail**។ យើងដឹងពីការចុះផ្សព្វផ្សាយពីមុននេះគឺជាការផ្លាស់ប្តូរដែលចង់បាន ដូច្នេះ ឥឡូវនេះ យើងកំពុងធ្វើការលើព័ត៌មានលម្អិតបច្ចេកទេស និងឱកាសផ្ទៃក្នុង។



ស្ថានីយ៍រថភ្លើងធន់ស្រាល Mt Baker Light Rail

2. យើងកំពុងសហការជាមួយក្រុមភ្នាក់ងារជាច្រើនដោយផ្តោតលើ **ការរៀបចំផែនការតំបន់ស្ថានីយ៍ Mt Baker** ដើម្បីកំណត់សកម្មភាពដែលអាចធ្វើទៅបាន និងជាក់ស្តែងដែលសម្របសម្រួលការវិនិយោគតាមរបៀបដែលត្រូវនឹងចក្ខុវិស័យរបស់សហគមន៍។ ដំណើរការនេះកំពុងត្រូវបានដឹកនាំដោយការិយាល័យរៀបចំផែនការ និងការអភិវឌ្ឍន៍សហគមន៍។